**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

~~~\*\*\*~~~

សាលាដំបូងខេត្តកណ្ដាល
សាលក្រមព្រហ្មទណ្ឌលេខ: **០៦៦(ន)**
ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០២៣

**តាងនាមប្រជារាស្ត្រខ្មែរ**
**សាលាដំបូងខេត្តកណ្ដាល**

បានបើកសវនាការជំនុំជម្រះជាសាធារណៈ នៅសាលាដំបូងខេត្តកណ្ដាល នៅថ្ងៃទី១០ ខែឧសភា ឆ្នាំ២០២៣ ដោយមានសមាសភាពដូចតទៅ:

**ចៅក្រមជំនុំជម្រះ**

លោក [redacted] ជាចៅក្រមជំនុំជម្រះនៃសាលាដំបូងខេត្តកណ្ដាល

**តំណាងអយ្យការ**

លោកស្រី [redacted] ព្រះរាជអាជ្ញារងអមសាលាដំបូងខេត្តកណ្ដាល

**ក្រឡាបញ្ជីសវនាការ**

លោក [redacted] ក្រឡាបញ្ជីនៃសាលាដំបូងខេត្តកណ្ដាល

**មេធាវី**

លោក [redacted] ជាមេធាវីការពារក្ដីឲ្យជនជាប់ចោទឈ្មោះ [redacted] **អូនតូច**

លោក [redacted] ជាមេធាវីការពារក្ដីឱ្យដើមបណ្ដឹង

ដើម្បីជំនុំជម្រះសំណុំរឿងព្រហ្មទណ្ឌលេខ: **១២៥៨** អក ចុះថ្ងៃទី០៦ ខែសីហា ឆ្នាំ២០២១ ដែលមានជនជាប់ចោទឈ្មោះ [redacted] **អូនតូច** ភេទស្រី អាយុ៣៤ឆ្នាំ សញ្ជាតិខ្មែរ មុខរបរមេផ្ទះ ទីកន្លែងកំណើតនៅភូមិ [redacted] ខេត្តព្រៃវែង និងទីលំនៅបច្ចុប្បន្ននៅភូមិ៣ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] ជាត (រ) ម្ដាយឈ្មោះ [redacted] យឿម (រ) ប្ដីឈ្មោះ [redacted] ចំរើន (រ) មានកូន ០៤នាក់ ជានីតិជន ទោសពីមុន គ្មាន ។ (ក្រៅឃុំ)

ពីបទៈ **ផិត** ប្រព្រឹត្តនៅភូមិកំពង់សំណាញ់ សង្កាត់កំពង់សំណាញ់ ក្រុងតាខ្មៅ ខេត្តកណ្ដាល កាលពីថ្ងៃទី២៦ ខែមេសា ឆ្នាំ២០២០ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្ដន្ទាទោសតាមបញ្ញត្តិមាត្រា១០នៃច្បាប់ស្ដីពីឯកពន្ធភាព ។

ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] ចំរើន ភេទប្រុស អាយុ ៤៥ឆ្នាំ មុខរបរ សាស្ត្រាចារ្យ ទីលំនៅបច្ចុប្បន្ននៅភូមិ៦ សង្កាត់ ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ។



Scanned with CamScanner
~~~

## ដំណើររឿងមានដូចតទៅ

កាលពីអំឡុងឆ្នាំ២០០៦ មានឈ្មោះ [redacted] ចំរើន បានរៀបអាពាហ៍ពិពាហ៍ជាមួយប្រពន្ធឈ្មោះ [redacted] អូនតូច រហូតដល់ឆ្នាំ២០១១ ដោយមានកូន ០៤នាក់ ទើបអ្នកទាំងពីរទៅចុះសំបុត្រអាពាហ៍ពិពាហ៍ ។ កាលពីថ្ងៃទី២៦ ខែមេសា ឆ្នាំ២០២០ ឈ្មោះ [redacted] ចំរើន និងសមត្ថកិច្ចខេត្តកណ្តាល បានទៅទាន់ឈ្មោះ [redacted] អូនតូច កំពុងតែប្រព្រឹត្តអំពើផិតជាមួយអ្នកដទៃ នៅក្នុងផ្ទះសំណាក់យីហោ មហាលាភ ស្ថិតនៅភូមិកំពង់សំណាញ់ សង្កាត់កំពង់សំណាញ់ ក្រុងតាខ្មៅ ខេត្តកណ្តាល បន្ទាប់មកសមត្ថកិច្ចបាននាំឈ្មោះ [redacted] អូនតូច ទៅធ្វើសាកសួរ ប៉ុន្តែដោយមានការព្រមព្រៀងគ្នាជាមួយឈ្មោះ [redacted] ចំរើន និងប្រពន្ធឈ្មោះ [redacted] អូនតូច ទើបសមត្ថកិច្ចបានឲ្យត្រឡប់ទៅផ្ទះវិញ ។ ក្រោយមកនៅថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០២០ ឈ្មោះ [redacted] ចំរើន និងប្រពន្ធឈ្មោះ [redacted] អូនតូច បានដាក់ពាក្យបណ្តឹងលែងលះគ្នានៅសាលាដំបូងរាជធានីភ្នំពេញ ហើយបណ្តឹងលែងលះនេះសាលាដំបូងរាជធានីភ្នំពេញមិនទាន់បានចេញសាលក្រមនៅឡើយទេ ចំណែកឈ្មោះ [redacted] អូនតូច នៅតែបន្តផិតក្បត់ដដែល ទើបតែនៅថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០២១ ឈ្មោះ [redacted] ចំរើន បានដាក់ពាក្យបណ្តឹងលែងលះប្រពន្ធម្តងទៀតនៅសាលាដំបូងរាជធានីភ្នំពេញ ប៉ុន្តែដោយអង្គហេតុបានកើតឡើងនៅខេត្តកណ្តាល ទើបតំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ចេញដីកាសម្រេចផ្ទេរសមត្ថកិច្ចលេខ ០១៥ អយខ ចុះថ្ងៃទី ០៤ ខែសីហា ឆ្នាំ២០២១ នៃសំណុំរឿងខាងលើបញ្ជូនមកកាន់អយ្យការអមសាលាដំបូងខេត្តកណ្តាល ដើម្បីចាត់ការតាមនីតិវិធីវិញ ។

## បានឃើញ

-ដីកាសន្និដ្ឋានស្ថាពរលេខៈ ៣៩០ ដក.សព ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២២ របស់អយ្យការអមសាលាដំបូងខេត្តកណ្តាល ។

-ដីកាដំណោះស្រាយលេខៈ ១២២១ ដកជស/២២ ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០២២ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តកណ្តាល ។

-ដីកាចាត់តាំងចៅក្រមជំនុំជម្រះលេខៈ ១៣២០ ដកចត/២២ ចុះថ្ងៃទី០២ ខែវិច្ឆកា ឆ្នាំ២០២២ របស់ប្រធានសាលាដំបូងខេត្តកណ្តាល ។

## នាពេលសវនាការ

-ក្រោយពីបានស្តាប់អំណានចម្លើយជនជាប់ចោទ

-ក្រោយពីបានស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី

-ក្រោយពីបានស្តាប់ការសន្និដ្ឋានទោសរបស់តំណាងអយ្យការ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារក្តីឲ្យជនជាប់ចោទ

-ក្រោយពីបានពិនិត្យភស្តុតាងនានា

-ក្រោយពីបានពិចារណាត្រឹមត្រូវតាមច្បាប់



Scanned with CamScanner

## សំអាងហេតុ

១-តាមអង្គហេតុបានបង្ហាញថា កាលពីថ្ងៃទី២៦ ខែមេសា ឆ្នាំ២០២០ ស្ថិតនៅភូមិកំពង់សំណាញ់ សង្កាត់កំពង់សំណាញ់ ក្រុងតាខ្មៅ ខេត្តកណ្តាល ពិតជាកើតមាននូវអំពើ ផិត ប្រាកដមែន ដែលអំពើនេះប្រព្រឹត្តឡើងដោយជនជាប់ចោទឈ្មោះ [redacted] អូនតូច បានធ្វើសកម្មភាពលបលួចរួមភេទជាមួយប្រុសថ្មី ទាំងដែលកំពុងមានចំណងអាពាហ៍ពិពាហ៍ជាមួយឈ្មោះ [redacted] ចំរើន ដែលជាប្តី ។

២-តាមអំណានចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] អូនតូច បានឆ្លើយថា៖ នៅថ្ងៃកើតហេតុ ប្តីរបស់ខ្លួនបានប្រើហិង្សាមកលើខ្លួន បន្ទាប់មកខ្លួនបានទៅញាំអីជាមួយមនុស្សមួយក្រុម ក្នុងនោះមានមិត្តខ្លួនម្នាក់ ក្រោយពីញាំអីរួចខ្លួនក៏បានត្រឡប់មកផ្ទះវិញ តែប្តីខ្លួនមិនព្រមបើកទ្វារឲ្យខ្លួនចូលផ្ទះទេ ពេលនោះមិត្តខ្លួនក៏បានបន្តនាំទៅញាំអីមួយកន្លែងទៀត ដោយមានប្រុសមានស្រី ។ ក្រោយមកខ្លួនក៏បានស្រវឹង ហើយបាត់បង់ស្មារតី ពេលភ្ញាក់ដឹងខ្លួនក៏ដឹងថាខ្លួននៅក្នុងផ្ទះសំណាក់ ។ ឃើញថា ចម្លើយនេះជាចម្លើយដោះសារមួយ ដែលឆ្លើយដើម្បីសម្រាលបន្ទុកដល់ខ្លួនតែប៉ុណ្ណោះ ពុំមានសាក្សីនិងភស្តុតាងដោះបន្ទុកគ្រប់គ្រាន់ដែលគប្បីលើកយកមកពិចារណាឡើយ ព្រោះថា ចម្លើយនេះមានភាពផ្ទុយគ្នាទៅនឹងចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី និងអង្គហេតុ ហើយម្យ៉ាងទៀតសមត្ថកិច្ចបានចុះទៅដល់កន្លែងកើតហេតុ និងបានឃើញជនជាប់ចោទកំពុងតែប្រព្រឹត្តបទល្មើស ។

៣-តាមចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ចំរើន បានបញ្ជាក់ថា៖ ខ្លួន និងប្រពន្ធឈ្មោះ [redacted] ត អូនតូច បានរៀបការជាមួយគ្នាតាមប្រពៃណីតាំងពីឆ្នាំ២០០៦ រហូតដល់ថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០១១ ទើបបានទៅចុះសំបុត្រអាពាហ៍ពិពាហ៍ ត្រឹមត្រូវតាមច្បាប់ ។ ក្រោយពីរៀបការរួចប្រពន្ធខ្លួនចេះតែដើរលេងមិនចូលផ្ទះ ដោយខ្លួនមានការសង្ស័យទើបធ្វើការតាមដានហើយបានដឹងថាប្រពន្ធខ្លួនបានលួចលាក់ប្រព្រឹត្តអំពើក្បត់ដោយសាហាយជាមួយឈ្មោះ [redacted] វិជ្ជ័យ នៅក្នុងផ្ទះសំណាក់មហាលាភ ស្ថិតនៅភូមិកំពង់សំណាញ់ សង្កាត់កំពង់សំណាញ់ ក្រុងតាខ្មៅ ខេត្តកណ្តាល ។ ឃើញថា ចម្លើយនេះអាចឲ្យតុលាការលើកយកមកពិចារណាបាន ព្រោះថា ចម្លើយនេះមានភាពស៊ីសង្វាក់ទៅនឹងអង្គហេតុ ដែលជាភស្តុតាងមួយដែលអាចដាក់បន្ទុកទៅលើជនជាប់ចោទ ។

៤-ទាំងអំណានរបស់ចម្លើយជនជាប់ចោទ , ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី និងភស្តុតាងនានាជាឯកសារពាក់ព័ន្ធ ដែលអាចកំណត់បានថា ជនជាប់ចោទពិតជាបានប្រព្រឹត្តបទល្មើសប្រាកដមែន ។

៥-មានភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់ដែលបញ្ជាក់ថា ជនជាប់ចោទពិតជាបានប្រព្រឹត្តបទល្មើស ប្រាកដមែន។

៦-អំពើរបស់ជនជាប់ចោទបានស្តែងឡើងដោយ មានចេតនាទៅរួមសេវនកិច្ចជាមួយបុរសដទៃ ដែលខ្លួននៅមានចំណងអាពាហ៍ពិពាហ៍ ដែលអំពើនេះច្បាប់កំណត់ថាជាបទល្មើសព្រហ្មទណ្ឌ និងមានចែងក្នុងមាត្រា១០ នៃច្បាប់ស្តីពីឯកពន្ធភាព ។

៧-ជនជាប់ចោទជានីតិជន ហើយបានប្រព្រឹត្តបទល្មើសដោយមានចេតនា និងការយល់ដឹងពីអំពើរបស់ខ្លួន ដូច្នេះជនទាំងនេះត្រូវទទួលខុសត្រូវនូវទង្វើដែលខ្លួនបានប្រព្រឹត្តចំពោះច្បាប់ ។



Scanned with CamScanner

៨-មានពិរុទ្ធភាពគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះ [redacted] អូនតូច ដែលមានសាវតាដូចខាងលើ ពីបទះ ផិត ប្រព្រឹត្តនៅភូមិកំពង់សំណាញ់ សង្កាត់កំពង់សំណាញ់ ក្រុងតាខ្មៅ ខេត្តកណ្តាល កាលពីថ្ងៃទី២៦ ខែមេសា ឆ្នាំ២០២០ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា១០នៃច្បាប់ស្តីពីឯកពន្ធភាព ។

៩-គប្បីតុលាការប្រកាសទណ្ឌកម្មលើជនជាប់ចោទក្នុងកំរិតដាក់ពន្ធនាគារ ៥ខែ ដោយពិចារណាទៅលើលើភាពធ្ងន់ស្រាលនៃបទល្មើស និងសកម្មភាពល្មើសរបស់ជនជាប់ចោទដូចខាងក្រោមៈ

-អំពើល្មើសរបស់ជនជាប់ចោទបានធ្វើឲ្យប៉ះពាល់ដល់ កិត្តិយស សេចក្តីថ្លៃថ្នូររបស់អ្នកដទៃ សណ្តាប់ធ្នាប់សាធារណៈ ទំនៀមទំលាប់ប្រពៃណី និងរបៀបរៀបរយសង្គម ជាខ្លាំង ។

-សកម្មភាពល្មើសពុំបង្កឲ្យមានព្យសនៈសកម្មធ្ងន់ធ្ងរឡើយ ។ មូលហេតុទាំងនេះហើយនាំឲ្យតុលាការ ពិចារណាប្រកាសទោសក្នុងកំរិតខាងលើដល់ជនជាប់ចោទ ។

១០-ដើមបណ្តឹងរដ្ឋប្បវេណីបានប្តឹងទាមទារសំណងជម្ងឺចិត្តចំនួន ១០០,០០០$ (ដប់ម៉ឺន)ដុល្លារអាមេរិក ឃើញថា បណ្តឹងនេះធ្វើឡើងមានលក្ខណៈត្រឹមត្រូវតាមមាត្រា១៣ , មាត្រា១៤ , មាត្រា១៥ , មាត្រា២១ និង មាត្រា២២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ដែលតុលាការអាចពិនិត្យនិងសម្រេចបានតាមមាត្រា២៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។ តាមការពិនិត្យឃើញថា ការទាមទាររបស់ដើមបណ្តឹងរដ្ឋប្បវេណី មានចំនួន ច្រើនដែលគប្បីតុលាការបន្ធូបន្ថយឲ្យបានសមស្របទៅនឹងទំហំព្យសនៈកម្មជាក់ស្តែង ។

១១-សេចក្តីសន្និដ្ឋានរបស់មេធាវីការពារក្តីឲ្យដើមបណ្តឹងរដ្ឋប្បវេណីៈ ឆ្លងកាត់តាមសវនាការរួចមក យោងតាមចម្លើយរបស់កូនក្តីខ្លួន និងការចុះពិនិត្យទៅដល់កន្លែងកើតហេតុ គឺពិតជាបានឃើញជនជាប់ចោទក្នុងសភាពអាក្រាតកាយជាមួយប្រុសម្នាក់ ប្រាកដមែន ។ ឃើញថា មានធាតុផ្សំដាក់បន្ទុកគ្រប់គ្រាន់ តាមមាត្រា ១០ នៃច្បាប់ឯកពន្ធភាព ។ ស្នើសុំឲ្យតុលាការផ្តន្ទាទោសលើជនជាប់ចោទតាមច្បាប់ និងស្នើសុំតាមការទាមទាររបស់ដើមបណ្តឹងរដ្ឋប្បវេណី ។ គប្បីតុលាការពិចារណា ។

១២-តំណាងអយ្យការធ្វើសេចក្តីសន្និដ្ឋានប្តឹងសុំៈ ក្រោយពីមានការសួរដេញដោលនាពេលសវនាការរួចមក តាមចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី ឃើញថា ដើមបណ្តឹងរដ្ឋប្បវេណី និងជនជាប់ចោទឈ្មោះ [redacted] អូនតូច បានរៀបការជាមួយគ្នាតាមប្រពៃណីតាំងពីឆ្នាំ២០០៦ រហូតដល់ថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០១១ ទើបបានទៅចុះសំបុត្រអាពាហ៍ពិពាហ៍ ក្រោយមកដើមបណ្តឹងក៏បានដឹងថាជនជាប់ចោទបានលួចលាក់ប្រព្រឹត្តអំពើក្បត់ ដោយសាហាយជាមួយឈ្មោះ [redacted] វិច្ឆ័យ នៅក្នុងផ្ទះសំណាក់មហាលាភ ស្ថិតនៅភូមិកំពង់សំណាញ់ សង្កាត់កំពង់សំណាញ់ ក្រុងតាខ្មៅ ខេត្តកណ្តាល ។ តាមការចុះពិនិត្យដល់កន្លែងកើតហេតុ គឺបានឃើញជនជាប់ចោទនៅជាមួយបុរសដទៃ ។ ឃើញថា មានភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់ទៅលើជនជាប់ចោទ ពីបទះផិត ប្រព្រឹត្តនៅភូមិកំពង់សំណាញ់ សង្កាត់កំពង់សំណាញ់ ក្រុងតាខ្មៅ ខេត្តកណ្តាល កាលពីថ្ងៃទី២៦ ខែមេសា ឆ្នាំ២០២០ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា១០នៃច្បាប់ស្តីពីឯកពន្ធភាព ។ រក្សាបទចោទតាមដីកាសន្និដ្ឋានស្ថាពរលេខ ៣៩០ ដក.សព ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២២ របស់អយ្យការអមសាលាដំបូងខេត្តកណ្តាល ស្នើសុំឲ្យតុលាការផ្តន្ទាទោសជនជាប់ចោទតាមច្បាប់ ។ គប្បីតុលាការពិចារណា ។



Scanned with CamScanner

១៣-សេចក្ដីសន្និដ្ឋានរបស់មេធាវីការពារក្ដីឲ្យជនជាប់ចោទ៖ ឆ្លងកាត់តាមសវនាការរួចមក តាមចម្លើយរបស់ដើមបណ្ដឹងរដ្ឋប្បវេណី ដែលបានថាកូនក្ដីខ្លួនទៅលួចលាក់ប្រព្រឹត្តអំពើក្បត់ សាហាយជាមួយឈ្មោះ [redacted] វិច្ឆ័យ នោះ គឺមិនមានសាក្សីណាបានឃើញឡើយ ។ ឃើញថា ជាវិមតិសង្ស័យ ដូច្នេះស្នើសុំឲ្យតុលាការ ឲ្យជនជាប់ចោទរួចខ្លួនពីបទចោទ ។ គប្បីតុលាការពិចារណា ។

**សម្រេច**

១-ផ្ដន្ទាទោសលើជនជាប់ចោទឈ្មោះ [redacted] អូនតូច ភេទស្រី អាយុ៣៨ឆ្នាំ សញ្ជាតិខ្មែរ មុខរបរមេផ្ទះ ទីកន្លែងកំណើតនៅភូមិកំ[redacted] ខេត្តព្រៃវែង និងទីលំនៅបច្ចុប្បន្ននៅភូមិ៣ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] ជាត (រ) ម្ដាយឈ្មោះ [redacted] យឿម (រ) ប្ដីឈ្មោះ [redacted] ស ចំរើន (រ) មានកូន ០៤នាក់ ជានីតិជន ទោសពីមុន គ្មាន ។(ក្រៅឃុំ)

*ដាក់ពន្ធនាគារកំណត់រយៈពេល ៥(ប្រាំ)ខែ និងពិន័យជាប្រាក់ ២០០.០០០៛ (ពីរសែនរៀល)* ពីបទ៖ ផិតប្រព្រឹត្តនៅភូមិកំពង់សំណាញ់ សង្កាត់កំពង់សំណាញ់ ក្រុងតាខ្មៅ ខេត្តកណ្ដាល កាលពីថ្ងៃទី២៦ ខែមេសា ឆ្នាំ២០២០ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្ដន្ទាទោសតាមបញ្ញត្តិមាត្រា១០ នៃច្បាប់ស្ដីពីឯកពន្ធភាព ។

២-បង្គាប់ឲ្យជនជាប់ចោទឈ្មោះ [redacted] អូនតូច ដែលមានសាវតាដូចខាងលើ សងសំណងជម្ងឺចិត្តជាប្រាក់ចំនួន ១០.០០០.០០០៛ (ដប់លានរៀល) ទៅឲ្យដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] ចំរើន សំណើរលើសពីនេះបដិសេធចោល ។

៣-សាលក្រមនេះប្រកាសជាសាធារណៈ នៅថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០២៣ ចំពោះដើមបណ្ដឹងរដ្ឋប្បវេណី និងកំបាំងមុខជនជាប់ចោទ បើកផ្លូវប្ដឹងទាស់ និងឧទ្ធរណ៍តាមកំណត់ច្បាប់ ។

**ក្រឡាបញ្ជីសវនាការ**
ហត្ថលេខា និងត្រា៖ [redacted]

**ចៅក្រមជំនុំជម្រះ**
ហត្ថលេខា និងត្រា៖ [redacted]

---

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
ថ្ងៃពុធ ៥កើត ខែជេស្ឋ ឆ្នាំថោះ បញ្ចស័ក ព.ស២៥៦៧
ធ្វើនៅកណ្ដាល ថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០២៣
**ក្រឡាបញ្ជី**

[redacted]

បានឃើញ
**ចៅក្រមជំនុំជម្រះ**

[redacted]



Scanned with CamScanner